

# សេចក្តីទុកចិត្ត

សេរីការ : មហាវិថីគ្មានទ្វារ វាបើកច្រកឱ្យអស់ផ្លូវតូចៗចូលបាន

សេចក្តីទុកចិត្ត គឺជាសេចក្តីអង់អាច។ វាក៏ជា ការបោះបង់ នូវចាគប័ត្រ[1] ផងដែរ។ សេចក្តីទុកចិត្ត គឺជាផ្នែកតែមួយ ហើយមិនអាចបំបែកបាន។

ធ្វើអ្វីមួយឱ្យមានជោគជ័យ គឺជាជោគជ័យ[2]។ ជោគជ័យនេះឯង ដែលតម្រូវឱ្យមានសេចក្តីទុកចិត្ត រវាង មេដឹកនាំ និង អធិនជន[3] និង សេចក្តីទុកចិត្ត លើខ្លួនឯង ហើយនឹង សេចក្តីទុកចិត្ត រវាងគ្នានិងគ្នា នៅក្នុងក្រុម។ គ្មានសេចក្តីទុកចិត្ត គឺគ្មានជ័យជំនះ។

រួមគ្នា ធ្វើកិច្ចការអ្វីមួយ វាប្រសើរជាងបង្ខំឱ្យធ្វើ។ តែរួមគ្នាបាន លុះត្រាតែមាន សេចក្តីទុកចិត្ត លើគ្នាទៅវិញទៅមក។ គំនិតនេះ ជាគំនិតសាមញ្ញបំផុត សំរាប់ការរស់នៅ ហើយវាក៏ជាសារជាតិដើម របស់មនុស្សលោកដែរ។ ការវិវត្តពី សង្គមអនារ្យធម៌ ទៅជា សង្គមអរិយធម៌ គឺផ្អែកលើមូលដ្ឋាន នៃសេចក្តី

---

[1] ចាគប័ត្រ : (résignation) ការលះបង់សិទ្ធអោយអ្នកណាម្នាក់, ការអត់ធ្មត់ទ្រាំទ្រ។

[2] ប្រយោគនេះ ជារបស់លោក ឧត្តមសេនីកងទ័ព Pierre de Villiers អតីត អគ្គមេសេនាធិការ នៃកងទ័ពបារាំង សរសេរនៅក្នុងសៀវភៅរបស់លោក មានចំណងជើងជាភាសាបារាំងថា : Qu’est-ce qu’un chef ?

[33] អធិនជន : អ្នកនៅក្រោមបង្គាប់។

ទុកចិត្តនោះឯង។ កាលសម័យបុរាណ ការជ្រើសរើស នៃមេកន្ទ្រាញ នៅក្នុងកុលសម្ព័ន្ធ ក៏ផ្អែកលើសេចក្ដីទុកចិត្ត ជាលក្ខណវិនិច្ឆ័យចំបង។

មេដឹកនាំ ត្រូវមានវិធីសាស្ត្រពីរយ៉ាង : ពិចារណា ជាភាពផ្ដេក, បែបពាក់ព័ន្ធ និង សំរាប់ប្រើការក្នុងកិច្ចការណាមួយ ហើយម្យ៉ាងទៀត ត្រូវពិចារណាដែរ ជាភាពបញ្ឈរ, បែបតាមឋានានុក្រម និង សំរាប់សម្រេចកិច្ចការណាមួយ។ ពិចារណាទី១ គឺសំរាប់ស្វែងរក ការចូលរួមដោយស្ម័គ្រចិត្ត ពីសំណាក់ បុគ្គលិក ឬ សមាជិកទាំងឡាយ នៅក្នុងកិច្ចការណាមួយ។ ពិចារណាទី២ គឺរៀបចំឱ្យមានផែនការពិតប្រាកដ និងគោលដៅច្បាស់លាស់ ហើយនឹងមាន ចក្ខុវិស័យ សំរាប់បំភ្លឺ យុទ្ធសាស្ត្រកំរិតទុក។ វិធីសាស្ត្រទាំងពីរនេះឯង ជាសិលាប្រធាន[4] នៃសុខដុមផង និង ដំណើរល្អផង សំរាប់ធ្វើកិច្ចការ ទើបក្រុម មានជោគជ័យ។ បើគេ ប្រៀបធៀបនឹងថ្នាក់ជាតិ គំនិតងាយស្រួល សំរាប់បញ្ជាក់បង្ហាញ នូវជោគជ័យជាតិ ដែលកើតពីសេចក្ដីទុកចិត្ត គឺសាមគ្គីភាព នៅក្នុងមូលដ្ឋាន នៃលទ្ធិប្រជាធិបតេយ្យ ព្រោះលទ្ធិនេះ វាបង្កើត លក្ខខណ្ឌមូលដ្ឋាន សំរាប់ធានា នូវសេរីភាព សមភាព និង ភាតរភាព ដែលជាមូលដ្ឋាន នៃសេចក្ដីទុកចិត្ត នៅក្នុងសង្គមជាតិ។ សង្គមជាតិ ជាសង្គមស្មុគ្រស្មាញក៏ថាបាន ជាសង្គមមានសណ្ដាប់ធ្នាប់ក៏ថាបាន។ ភាពស្មុគ្រស្មាញនេះឯង

[4] ជាសិលាប្រធាន : Clé de voute.

# សេចក្តីទុកចិត្ត

តម្រូវឱ្យមានការរៀបចំ ដើម្បីឱ្យមានសណ្តាប់ធ្នាប់ ដែលមានកើត ទំនៀមទំលាប់ រួចបន្តបង្កើត ជាច្បាប់ សំរាប់គ្រប់គ្រងសង្គម។ គ្រប់គ្រងសង្គម គឺគ្រប់គ្រងមនុស្ស នៅក្នុងគំនិតមូលដ្ឋាន គឺការរួបរួម សំរាប់សុភមង្គល នៃបុគ្គលម្នាក់ៗ នៅក្នុងសង្គម, ដូច្នេះឯង បុគ្គលម្នាក់ៗ ត្រូវចាំបាច់ចូលរួម ក្នុងកិច្ចការរួម ដើម្បីយល់ដឹងបាន អំពីកំរិតផលាវាស់បាន នៃភាតកម្ម របស់ខ្លួន។ តែនៅក្នុងកិច្ចការរួមនោះ ត្រូវមានចក្ខុវិស័យច្បាស់លាស់ និង ផែនការយុទ្ធសាស្រ្ត ដែលកំណត់គោលដៅ។

នុះឯង ជាសេចក្តីពិតសាមញ្ញ គឺ សេចក្តីទុកចិត្ត ព្រោះវា ជាផលា របស់ការកើតឡើង នៃការចូលរួមដោយស្ម័គ្រចិត្ត។ ហេតុនេះឯង បានជាគេ ត្រូវចាំបាច់ចិញ្ចឹម ជាអចិន្ត្រៃយ៍ នូវគំនិតនៃការចូលរួមដោយស្ម័គ្រចិត្ត សំរាប់គោលដៅរួម។ ដូច្នោះ គេអាចនិយាយ ជាពាក្យប្រៀបបានថា សេចក្តីទុកចិត្ត វាជា ចលករ នៃជោគជ័យ ព្រោះ វាជា កម្លាំងប្រមូលផង និង ធ្វើឱ្យដើរផង។ កម្លាំង នៃសេចក្តីទុកចិត្តនេះ មិនមែន ជាកម្លាំង សំរាប់គោរពបុគ្គល ឬ វត្ថុអ្វីមួយនោះឡើយ គឺវាជា កម្លាំងឈានទៅមុខ ក្នុងគោលដៅរួម សំរាប់ជោគជ័យរួម៕